# លិខិតអញ្ជើញ
## សមាជិកនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC)

**កម្មវត្ថុ៖** អញ្ជើញចូលរួមសិក្ខាសាលាអប់រំផ្សព្វផ្សាយស្តីពី "បច្ចុប្បន្នភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធបរិស្ថានសម្រាប់វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ផលិតស្បែកជើង និងកាបូប"

សេចក្តីចែងដូចមានក្នុងកម្មវត្ថុខាងលើ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា មានកិត្តិយសសូមជម្រាបជូនសមាជិកទាំងអស់ឱ្យបានជ្រាបថា សមាគមនឹងមានការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **"បច្ចុប្បន្នភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធបរិស្ថានសម្រាប់វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ផលិតស្បែកជើង និងកាបូប"** ក្នុងគោលបំណងផ្សព្វផ្សាយ និងជម្រុញលើការពង្រឹងការអនុវត្តច្បាប់ស្តីពីបរិស្ថាន ជាពិសេសផ្តោតសំខាន់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងវិស័យឧស្សាហកម្ម។ សិក្ខាសាលានេះនឹងប្រព្រឹត្តទៅតាមពេលវេលា និងទីកន្លែងដូចខាងក្រោម៖

**កាលបរិច្ឆេទ** ៖ ថ្ងៃច័ន្ទ ទី២៥ ខែមិថុនា ឆ្នាំ២០១៨
**ពេលវេលា** ៖ ម៉ោង ៩:០០ នាទីព្រឹក ដល់ ១២:០០ថ្ងៃត្រង់
**ទីកន្លែង** ៖ ការិយាល័យសមាគមរោងចក្រកាត់ដេរនៅកម្ពុជា, តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។
**ភាសា** ៖ ភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាចិន

សិក្ខាសាលានេះមានការចូលរួមពីសំណាក់វាគ្មិនដែលអញ្ជើញមកពី ក្រសួងបរិស្ថាន និង ក្រុមហ៊ុន Beetle Environmental Solutions ដែលជាក្រុមហ៊ុនពិគ្រោះយោបល់អំពីបរិស្ថាននៅកម្ពុជា។

សម្រាប់ការចុះឈ្មោះ និងព័ត៌មានបន្ថែម សមាគមស្នើសុំសមាជិកទាំងអស់ចុះឈ្មោះចូលរួមឱ្យបានមុនថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ តាមរយៈទូរស័ព្ទលេខ៖ **០៨៩ ៧០០ ៩៩៥** ឬ **០៨៨ ៨១ ២២ ១៣៣** ឬ សារអេឡិចត្រូនិច៖ sokphirum@gmac-cambodia.org ។

**បញ្ជាក់៖ ចំពោះការចូលរួមរបស់បណ្តារោងចក្រនីមួយៗដែលជាសមាជិកនៃសមាគមអាចចូលរួមបាន ២រូប។**

រាជធានីភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ទី១៤ ខែមិថុនា ឆ្នាំ២០១៨

GARMENT MANUFACTURERS ASSOCIATION IN CAMBODIA

Garment Manufacturers Association in Cambodia

# សិក្ខាសាលាអប់រំផ្សព្វផ្សាយ

# ស្តីពី

# បច្ចុប្បន្នភាពនៃការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធបរិស្ថានសម្រាប់
# វិស័យឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ផលិតស្បែកជើង និងកាបូប

**កាលបរិច្ឆេទ** ៖ ថ្ងៃទីច័ន្ទ ទី២៥ ខែមិថុនា ឆ្នាំ២០១៨

**ទីកន្លែង** ៖ សមាគមរោងចក្រកាត់ដេរនៅកម្ពុជា តំបន់ឧស្សាហកម្មពិសេសភ្នំពេញ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ។

**ទូរស័ព្ទទំនាក់ទំនង** ៖ **០៨៩ ៧០០ ៩៩៥/ ០៨៨ ៨១ ២២ ១៣៣**

**អ៊ីម៉ែល** ៖ sokphirum@gmac-cambodia.org

| ល.រ | ពេលវេលា | សកម្មភាព | សម្របសម្រួល |
|---|---|---|---|
| ១ | ៨:០០ - ៩:០០ | អ្នកចូលរួមអញ្ជើញមកដល់ និងការចុះបញ្ជីវត្តមានអ្នកចូលរួម | ផ្នែកទទួលភ្ញៀវ |
| ២ | ៩:០០ - ៩:០៥ | មតិស្វាគមន៍ និងការសម្តែងហេតុ | **តំណាងនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា** |
| ៣ | ៩:០៥ - ១០:០០ | ការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងបរិស្ថាន (សំនួរ និងចម្លើយ) | **លោក សុខ អូរ៉ែ** អនុប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន |
| ៤ | ១០:០០ - ១០:៣០ | សម្រាកទទួលទានកាហ្វេ | ផ្នែកទទួលភ្ញៀវ |
| ៥ | ១០:៣០ - ១១:៣០ | ដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (សំនួរ និងចម្លើយ) | **អ្នកស្រី ភាន់ឡា សុវិតា** ប្រធានក្រុមនៃក្រុមហ៊ុន Beetle Environmental Solutions |
| ៦ | ១១:៣០ - ១២:៣០ | សម្រាកទទួលទានអាហារថ្ងៃត្រង់ | ផ្នែកទទួលភ្ញៀវ |

**បញ្ជាក់:** **កម្មវិធីនេះអាចនឹងមានការប្រែប្រួលក្នុងករណីចាំបាច់។**